ក

# មាតិកា

## I.ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០១-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៣៥៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និង អស់លោក ចំនួន ១៨ រូប ៣៨២៦

០១-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៣៥៩ ស្តីពី ការតែងតាំងឯកឧត្តមចំនួន ០៥ រូប ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី ៤ បន្ថែមលើមុខងារបច្ចុប្បន្ន ៣៨២៧

០១-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៣៦០ ស្តីពី ការតម្លើងឋានៈឯកឧត្តមចំនួន ០៤ រូប បច្ចុប្បន្នជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី ៤ មានឋានៈស្មើ រដ្ឋលេខាធិការ ៣៨២៨

០៣-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៣៦១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះអ្នកឧកញ៉ា,ឯកឧត្តម និង អស់លោក ចំនួន ១៨ រូប ៣៨២៩

០៣-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៣៦២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និង អស់លោក ចំនួន ១៩ រូប ៣៨៣០

០៧-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៣៦៦ ស្តីពី ការតែងតាំងលោក **ជា ទ្រី** ជាឧកញ៉ា ៣៨៣១

០៧-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៣៦៧ ស្តីពី ការតែងតាំងឯកឧត្តម **ឱម យ៉ិនទៀង** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ៣៨៣២

០៧-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៣៦៨ ស្តីពី ការតែងតាំងឯកឧត្តម **ស៊ាន ប៉ូរ៉ាត** ជាអនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ មានឋានៈស្មើ រដ្ឋមន្ត្រី ៣៨៣៣

០៧-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៣៦៩ ស្តីពី ការផ្លាស់ឯកឧត្តម **លឹម សំគុល** បច្ចុប្បន្នឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ វិលចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម ៣៨៣៤

០៧-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៣៧០ ស្តីពី ការតែងតាំងឯកឧត្តម **ចាន់ គីស៊ីម** បច្ចុប្បន្នទីប្រឹក្សាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ ៣៨៣៥

០៧-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៣៧១ ស្តីពី ការផ្លាស់ឯកឧត្តម ម៉ាន់ ផល ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម វិលចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម ៣៨៣៦

០៧-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៣៧២ ស្តីពី ការតែងតាំងឯកឧត្តម ហ៊ុល ផានី បច្ចុប្បន្នទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម ៣៨៣៧

## II. រាជរដ្ឋាភិបាល

### អនុក្រឹត្យ

០៦-៥-២០១០ -អនុក្រឹត្យលេខ ៥១៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨៣៨

០៦-៥-២០១០ -អនុក្រឹត្យលេខ ៥១៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨៤០

០៧-៥-២០១០ -អនុក្រឹត្យលេខ ៥១៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨៤១

០៧-៥-២០១០ -អនុក្រឹត្យលេខ ៥១៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨៤១

០៧-៥-២០១០ -អនុក្រឹត្យលេខ ៥១៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៨៤៣

០៧-៥-២០១០ -អនុក្រឹត្យលេខ ៥១៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣៨៤៤

០៧-៥-២០១០ -អនុក្រឹត្យលេខ ៥១៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣៨៤៥

០៧-៥-២០១០ -អនុក្រឹត្យលេខ ៥២០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៨៤៦

០៧-៥-២០១០ -អនុក្រឹត្យលេខ ៥២១ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៣៨៤៧

១០-៥-២០១០ -អនុក្រឹត្យលេខ ៥២២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨៤៨

១០-៥-២០១០ -អនុក្រឹត្យលេខ ៥២៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨៤៩

១០-៥-២០១០ -អនុក្រឹត្យលេខ ៥២៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៨៥០

១០-៥-២០១០ -អនុក្រឹត្យលេខ ៥២៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៨៥១

១១-៥-២០១០ -អនុក្រឹត្យលេខ ៥២៦ អនក្រ.តត ស្តីពី ការបញ្ចូលក្របខ័ណ្ឌ នាយទាហាន ៣៨៥២

១១-៥-២០១០ -អនុក្រឹត្យលេខ ៥២៧ អនក្រ.តត ស្តីពី ការដាក់ឱ្យចូលនិវត្តន៍ និង តែងតាំងមន្ត្រីរាជការ ៣៨៥៣

១១-៥-២០១០ -អនុក្រឹត្យលេខ ៥២៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨៥៤

## III. ការងារបណ្តាក្រសួង

### ១. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

៣០-៤-២០១០ -ប្រកាសលេខ ៣២៧ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អាជីណូម៉ូតូ (ខេមបូឌា) បង្កើតរោងចក្រ ផលិតប៊ីចេង និង គ្រឿងផ្សំបន្ថែមរសជាតិ ៣៨៥៥

## ២_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៩-៧-២០០៩ -លិខិតបញ្ជាក់លេខ ២៧៩៨ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យុន ហុង (ខេមបូឌា) អ៊ិមផត អិចផត** ៣៨៥៩

០៩-៧-២០០៩ -លិខិតបញ្ជាក់លេខ ២៧៩៩ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ាយធីឌី (ខេមបូឌា)** ៣៨៦១

០៩-៧-២០០៩ -លិខិតបញ្ជាក់លេខ ២៨០០ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យូណាយធីត ហ្វាម៉ា (ខេមបូឌា)** ៣៨៦៣

០៩-៧-២០០៩ -លិខិតបញ្ជាក់លេខ ២៨០១ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តេីហ្វីត ឌីហ្សាញ អេន ខនសាល់ធេន អ៊ិនជីនារីង** ៣៨៦៥

០៩-៧-២០០៩ -លិខិតបញ្ជាក់លេខ ២៨១០ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទ្រី ប៊ុនថេង** ៣៨៦៧

០៩-៧-២០០៩ -លិខិតបញ្ជាក់លេខ ២៨១២ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យូ ធី ជី ខូ អិលធីឌី** ៣៨៦៩

១០-៧-២០០៩ -លិខិតបញ្ជាក់លេខ ២៨១៤ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជី ផាតធី ផ្លេននើ** ៣៨៧១

# ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៣៥៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

| | |
|---|---|
| ១-ឯកឧត្តមឧត្តមសេនីយ៍ទោ អ៊ិន ប៊ូរ៉ា | ២-ឯកឧត្តម ជា ប៉េងឈាង |
| ៣-ឯកឧត្តមឧត្តមសេនីយ៍ទោ ជា ណារ៉ែត | ៤-លោកវរសេនីយ៍ឯក ពិន សំអាត |
| ៥-លោកវរសេនីយ៍ទោ ឡៅ សុគិរៈ | ៦-លោកវរសេនីយ៍ត្រី ណុព្វ ស៊ីនិត |

ខ-គ្រឿងឥស្សរិយយស **សេនាជ័យសិទ្ធ** ចំពោះ :

១-ឯកឧត្តមឧត្តមសេនីយ៍ត្រី ឃិន គីមអាន

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

| | |
|---|---|
| ១-លោក សៀម សុជា | ២-លោក សុខ ពៅ |
| ៣-លោកវរសេនីយ៍ត្រី ឈុន គឹមហេង | ៤-លោក អោម ផល្លី |
| ៥- លោកស្រី ហ៊ឹម សូរីដា | ៦-លោក ទេព រាមមុនី |
| ៧-លោក ហ៊ុំ ធន់ | ៨-លោក កែប ឆា |
| ៩-លោក គង់ សារឿន | ១០-លោក ប៊ុន ពៅ |

ឃ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

១-លោកវរសេនីយ៍ទោ គៅ ប៊ុនគីម

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣/ល. ១០០៥.៣៦២

លេខ: ៣៣៥ ច.ល
[illegible]ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible]ឌិនកេន

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១០*

# ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៣៥៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានតែងតាំង :

១- **ឯកឧត្តម លឹម ថៃអាង** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

២- **ឯកឧត្តម វៀល មួន** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

៣- **ឯកឧត្តម ឡៅ គង់** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

៤- **ឯកឧត្តម ភួង ជា** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

៥- **ឯកឧត្តម សំ សារ៉ាត់** ជាជំនួយការសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា២** : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រ៧.១០០៥.៣៦៣

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១០*

លេខៈ ៣៣៤ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ២០១០

**[illegible]រាជរដ្ឋាភិបាល**

**[illegible] ចិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៣៦០

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

<u>មាត្រា១</u> : ត្រូវបានតម្លើងឋានៈ

១- **ឯកឧត្តម ហេង បូរ៉ា** បច្ចុប្បន្នជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានីតិកាលទី៤មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

២- **ឯកឧត្តម ច័ន្ទ ចណ្ណៈ** បច្ចុប្បន្នជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានីតិកាលទី៤មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

៣- **ឯកឧត្តម ឈឹម ណែម** បច្ចុប្បន្នជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានីតិកាលទី៤មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

៤- **ឯកឧត្តម រំុប សុធី** បច្ចុប្បន្នជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានីតិកាលទី៤មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

<u>មាត្រា២</u> : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

<u>មាត្រា៣</u> : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**

**នរោត្តម សីហមុនី**

*៣/ល.១០០៥.៣៦៤*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១០*

**លេខ:៣៣៣ ច.ល**

**ចម្លងចេញពីច្បាប់ដើម**

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible stamp]

**ស៊ុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៣៦១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន**

ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១-អ្នកឧកញ៉ា ឃួន សៀ ២-ឯកឧត្តម ជីម គេង

៣- ឯកឧត្តមយ៉េត ចរិយា ៤-ឯកឧត្តម សួង ភឿន

៥-ឯកឧត្តមឧត្តមសេនីយ៍ទោ មាស ចិរិទ្ធ ៦-ឯកឧត្តមឧកញ៉ា ជឹង ឆានគាត

៧-ឯកឧត្តម អ៊ូម សុធី ៨-ឧត្តមសេនីយ៍ត្រី ជួង ស៊ាងហាក់

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះ :

១- លោក គង់ ជុងហេង ២-លោក អេង យ៉ាន

៣-លោកវរសេនីយឯក ឡោ ចណ្ណចក្រ ៤-លោកវរសេនីយត្រី ឯម កុសល

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ចំពោះ :

១-លោកវរសេនីយទោ គង់ សុខុម ២-លោកជំទាវ ម៉ាន់ ណាវី

៣-លោក អ៊ុត សុភាព ៤-លោក សៀង ឫទ្ធី

៥-លោកវរសេនីយត្រី សន ធុត្ថា ៦-លោកវរសេនីយត្រី ស្វាយ ស៊ីប៊ុណ្ណា

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**

**នរោត្តម សីហមុនី**

*៣រល.១០០៥.៣៦៥*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១០*

លេខ: ៣៣៦ ច.ល

ដើម្បីចម្លងចែក

ភ្នំពេញ ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible]

# ព្រះរាជក្រឹត្យ

នស/រកត/០៩១០/៣៦៤

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ទូវ

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

1-Professor Dr.Dong-Myung Kim 2-Dr.Kenneth Malcolme Allen
3-Dr.Kasit Phisitkul 4-Dr.Kim Dong Su

ខ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

១-លោកវរសេនីយត្រី មួ ចណ្ឌារ័ត្ន

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ចំពោះ :

១-លោក ឈូត សៅ ២-លោក ម៉ាន់ កុសល
៣-លោក ទូយ សៅ ៤- លោក ឡឹត សំអឿន
៥-លោក សៀ គឹមសាន ៦-លោកវរសេនីយទោ តាប់ លន
៧- លោកអនុសេនីយឯក លន់ លាភ ៨-លោកអនុសេនីយទោ សុខ ផាត

ឃ-គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន**

ថ្នាក់ **អស្សឫទ្ធិ** ចំពោះ :

១- ឯកឧត្តម **គាំម** កុសល ២- ឯកឧត្តម **វ៉ាំង** ចណ្ណា
៣- ឯកឧត្តម **កែវ** ពិសិដ្ឋ ៤- ឯកឧត្តម **កែ** ប៊ុនខៀង
៥- ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ជា ចំរើន ៦-ឯកឧត្តមសាស្ត្រាចារ្យ ជាំ ម៉េងហុត

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.១០០៥.៣៦៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១០

លេខ:៣៣៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
[illegible] ជិនគេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៣៦៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

លោក ជា ទ្រី

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣/ល. ១០០៥. ៣៧០

លេខ: ៣៥៧ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១០

[illegible] ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ប៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៩១០/៧៦៧

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានតែងតាំងឯកឧត្តម **អ៊ឹម ឈុនលឹម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣/ល.១០០៥. ៣៧១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១០

លេខ: ៣៥១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ជីនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៣៦៧

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១០ ដែលប្រកាសអោយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ស៊ាន បូរ៉ាត** ជាអនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ មានឋានៈស្មើ រដ្ឋមន្ត្រី ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១០*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣/ល.១០០៥.៣៧២

លេខ:៣៥០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] ខិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៣៦៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានផ្លាស់ឯកឧត្តម **លឹម សំគុល** បច្ចុប្បន្នឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ វិលចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣.ល. ១០០៥. ៣៧៣

**លេខ: ៣៤៩ ច.ល**
**ដើម្បីចម្លងចែក**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១០

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១០

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ស៊ុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៣៧០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងឯកឧត្តម **ចាន់ គីស៊ីម** បច្ចុប្បន្នទីប្រឹក្សាក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋភូមា ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*៣រ.ល. ១០០៥. ៣៧៤*

លេខ: ៣៤៨ ច.ល

**ដើម្បីចម្លងចែក**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១០*

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១០

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៣៧២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតក្ខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានផ្លាស់ឯកឧត្តម **ម៉ាន់ ផល** ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម វិលចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*៣វល. ១០០៥. ៣៧៥*

លេខ: ៣៤៧ ច.ល

ដើម្បីចម្លងចែក

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១០* រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ជិនកេន**

# ព្រះរាជក្រឹត្យ

## យើង

នស/រកត/០៥១០/៣៧៤

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងឯកឧត្តម **ហ៊ុល ផានី** បច្ចុប្បន្នទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម ។

**មាត្រា ២** : សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ។

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣/ល.១០០៥.៣៧៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១០*

លេខ:៣៤៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**[illegible] ចិនកេន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥១៤. អនក្រ. បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន ១៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ សាលាធម្មសភា កុដិឈើរៀបឥដ្ឋក្រោម ០១ខ្នង មាន ០២ជាន់ កុដិឈើ ០២ខ្នង បណ្ណាល័យ ០១ខ្នង ស្រះទឹក ខ្លោងទ្វារ អាងទឹក ស្ពានចូលព្រះវិហារ និងចាក់ដីក្នុងទីធ្លាវត្ត ស្ថិតនៅវត្តអង្គស្វាយពុំសែន ឃុំដំបូកខ្ពស់ ស្រុកអង្គរជ័យ ខេត្តកំពត ដូចមានរាយព្រះនាម និង នាមខាងក្រោម៖

**ក-មេដាយមាសស្ថាបនាជាតិៈ**

- ព្រះតេជគុណ **ង៉ាស់ នេម** ព្រះចៅអធិការវត្តអង្គស្វាយពុំសែន បច្ច័យ ១០.១៥០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិៈ**

១- លោក **ឈុន សំណាង** សប្បុរសជននៅខេត្តកំពត ថវិកា ៥.០២០ ដុល្លារ

២- ឧបាសក **យិន ភ្លេក** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកា ៥.០១៥ ដុល្លារ

**គ-មេដាយសំរិទ្ធស្ថាបនាជាតិៈ**

១- ព្រះតេជគុណ **យន់ ភ្លឿន** គង់នៅវត្តអង្គស្វាយពុំសែន បច្ច័យ ២.០០០ ដុល្លារ

២- ព្រះតេជគុណ **ទែម សុនេត្តោ** គង់នៅវត្តអង្គស្វាយពុំសែន បច្ច័យ ១.៩២០ ដុល្លារ

| | | | | |
|---|---|---|---|---|
| ៣- | ឧបាសិកា | លឹម នៀគៀង | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកា ២.៣៥០ ដុល្លារ |
| ៤- | ឧបាសិកា | ទេព ប៊ិច | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ២.៣១០ ដុល្លារ |
| ៥- | លោក | យស់ សារ៉េត | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ២.០៥០ ដុល្លារ |
| ៦- | ឧបាសិកា | អេង ហុង | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១.៥៥០ ដុល្លារ |
| ៧- | លោក | ឆាង ចូច | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១.៥៤០ ដុល្លារ |
| ៨- | លោក | សុខ ឧ៉ារី | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១.៥០០ ដុល្លារ |
| ៩- | លោក | គុយ សុខុម | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១.២៣០ ដុល្លារ |
| ១០- | លោក | ហ៊ុយ ដារី | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១.១៧០ ដុល្លារ |
| ១១- | លោក | មាស ខុម | សប្បុរសជននៅខេត្តកណ្តាល | ថវិកា ១.១០០ ដុល្លារ |
| ១២- | លោក | អ៊ុក ហម | សប្បុរសជននៅខេត្តកំពត | ថវិកា ១.០០០ ដុល្លារ |
| ១៣- | លោក | អ៊ឹម ង៉ាក | សប្បុរសជននៅខេត្តកំពត | ថវិកា ១.០០០ ដុល្លារ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៥១៥ អនក្រ.បក**

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ជូនលោក អ៊ុខ ហៃម៉ៅ សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចំនួន ៦៧.៥០០ ដុល្លារអាមេរិក ជួយកសាងសមិទ្ធផលនានាលើវិស័យអប់រំ សុខាភិបាល ធារាសាស្ត្រ និង រចនាសម្ព័ន្ធគមនាគមន៍ ស្ថិតក្នុងឃុំម្កាក់ និងឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា២ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៥៦៦ . អនក្រ.បក**

# អនុក្រឹត្យ

# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកណ្តាល

## សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ១១រូប ដែលបានចំណាយធនធានផ្ទាល់ខ្លួនចូលរួមកសាង បណ្ណាល័យ នៅវត្តវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដូចមាននាយនាមខាងក្រោមៈ

**ក-មេដាយមាសស្ថាបនាជាតិៈ**

| | | | |
|---|---|---|---|
| ១- | លោក | អ៊ុច ច័ន្ទសត្យា | សប្បុរសជននៅរាជធានីភ្នំពេញ |
| ២- | លោក | សាន សៀនហ្វ | សប្បុរសជននៅខេត្តបន្ទាយមានជ័យ |
| ៣- | លោកយាយ | តាំង សៀមលួន | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៤- | ឧបាសក | យូ ជា | សប្បុរសជននៅខេត្តកណ្តាល |
| ៥- | លោកអាចារ្យ | ប្រាក់ ថាន់ | សប្បុរសជននៅខេត្តកណ្តាល |
| ៦- | លោកអាចារ្យ | ម៉ាន ម៉ុន | សប្បុរសជននៅខេត្តកណ្តាល |

**ខ-មេដាយប្រាក់ស្ថាបនាជាតិៈ**

| | | | |
|---|---|---|---|
| ១- | អ្នកស្រី | ពិន ធីតា | សប្បុរសជននៅរាជធានីភ្នំពេញ |
| ២- | លោកយាយ | លឿន ចាន់ | សប្បុរសជននៅរាជធានីភ្នំពេញ |

៣- ឧបាសក ជា កែប សប្បុរសជននៅខេត្តកណ្តាល

៤- លោកអាចារ្យ មិ ម៉ុន សប្បុរសជននៅខេត្តកណ្តាល

៥- លោកអាចារ្យ ឡុង ឡាន សប្បុរសជននៅខេត្តកណ្តាល

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលនៃគណៈអភិបាល ខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ** ជូននាយនគរបាល នៃ នាយកដ្ឋាននគរបាលការពារ ប្រចាំទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន០២រូប ដែលមានស្នាដៃល្អនិងស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការបំពេញភារកិច្ចការពារសន្តិសុខ ទីស្តីការគណៈរដ្ឋមន្ត្រី ដូចមានរាយនាមខាងក្រោម ៖

១-វរសេនីយ៍ឯក **ដើក ឌុន** អត្តលេខ ០៥៩៨ អនុប្រធាននាយកដ្ឋាន

២-វរសេនីយ៍ឯក **ម៉ែន ទណ្ណា** អត្តលេខ ០១០៧៨ អនុប្រធាននាយកដ្ឋាន

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥១៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូននាយនគរបាល នាយនគរបាលរង និងពលនគរបាល នៃនាយកដ្ឋាននគរបាលការពារ ប្រចាំទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន០៤រូប ដែលមានស្នាដៃល្អនិងស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការបំពេញភារកិច្ចការពារសន្តិសុខ ទីស្តីការគណៈរដ្ឋមន្ត្រី ដូចមានរាយនាមខាងក្រោម ៖

១-វរសេនីយ៍ទោ ម៉ៅ ច័ន្ទតារា អត្តលេខ ០៦២៥២ នាយរងផ្នែក

២-អនុសេនីយ៍ត្រី គង់ ស៊ីមន អត្តលេខ ៣២៨៦១ មន្ត្រី

៣-ព្រិន្ទបាលទោ អ៊ុច ស្នា អត្តលេខ ៣៨៦៨២ មន្ត្រី

៤-វរសេនីយ៍ត្រី ម៉ែន សុផល អត្តលេខ ០៧២១០ នាយផ្នែក

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥១៩ .អនក្រ.តត

## អនុក្រឹត្យ
## ស្ដីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន០៦រូប នៃមន្ទីរធម្មការនិងសាសនា ខេត្តកោះកុង ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជាច្រើនឆ្នាំកន្លងមក លើវិស័យធម្មការនិងសាសនា ជូនក្រសួង ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ:**

| | | |
|---|---|---|
| ១-លោក | សំ ធឿន | អនុប្រធានមន្ទីរធម្មការនិងសាសនា ខេត្តកោះកុង |
| ២-លោក | ឯក ឆុង | អនុប្រធានមន្ទីរធម្មការនិងសាសនា ខេត្តកោះកុង |

**ខ-មេដាយប្រាក់ការងារ:**

| | | |
|---|---|---|
| ១-លោកស្រី ទ៉ា | រ៉ាទី | ប្រធានការិយាល័យរដ្ឋបាល |
| ២-លោក | ជេង ស៊ីផាន់ | ប្រធានការិយាល័យសាសនសិក្សាធិការ |

**គ-មេដាយសំរិទ្ធការងារ:**

| | | |
|---|---|---|
| ១-លោក | ទុយ បុល | អនុប្រធានការិយាល័យធម្មការ |
| ២-លោក | សួន មាន | មន្ត្រីធម្មការ |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៧០.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ ជូនលោក SCOTT LEIPER សប្បុរសជន ជនជាតិអាមេរិក ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចំនួន ១៧០.០០០ ដុល្លារអាមេរិក ជួយកសាងសមិទ្ធផលនានា លើវិស័យអប់រំ សុខាភិបាល ធារាសាស្ត្រ និងរចនាសម្ព័ន្ធគមនាគមន៍ ស្ថិតក្នុងឃុំម្កាក់ និងឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៧១ . អនក្រ . បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយសហមេត្រី តាមលំដាប់ថ្នាក់ ចំនួន ០២គ្រឿង ជូនឥស្សរជនបារាំង ចំនួន ០២រូប ដែលមានស្នាដៃល្អក្នុងការ ចូលរួមជួយសាងសង់មណ្ឌលកុមារកំព្រា ខេត្តព្រះវិហារ ដូចមានរាយនាមខាងក្រោមៈ

**ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទៈ**

- ឯកឧត្តម Jean-François DESMAZIERES ឯកអគ្គរដ្ឋទូតបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា

**ខ-មេដាយសហមេត្រី ថ្នាក់ សេនាៈ**

- លោក Etienne ROUSSEL ប្រធានអង្គការកុមារអាស៊ីរអាស្តេកា ប្រចាំប្រទេសបារាំង

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ [illegible] ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥២៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០៤គ្រឿង ជូនសប្បុរសជននិងអង្គការ ដែលបានជួយសាងសង់ជួសជុលមណ្ឌលសុខភាព និងផ្តល់សំភារៈបរិក្ខារពេទ្យ ព្រមទាំងឧបត្ថម្ភគាំទ្រសកម្មភាពសុខាភិបាលក្នុងខេត្តបន្ទាយមានជ័យ តាមរយៈអង្គការ RACHA ចំណាយថវិកាចំនួន ៨៣២.៨០៦,៤៦ ដុល្លារអាមេរិក និង តាមរយៈអង្គការ URC ចំណាយថវិកាចំនួន ១.១៦២.៩៨៦,៥៦ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម ៖

១-អង្គការ ASSOCIATION AVENNIR POUR L'ENFANCE នៅប្រទេសបារាំង ជាម្ចាស់ជំនួយ
២-អង្គការ RACHA ម្ចាស់ជំនួយ
៣-លោក CHTAL ET HENRI LUZ សប្បុរសជននៅប្រទេសបារាំង
៤-លោក ALIAN MONTANE' សប្បុរសជននៅប្រទេសកម្ពុជា ជាអ្នកស្នើសុំជំនួយ

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល និង អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥២៣ .អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
